សិក្ខាកាមខ្មែរដែលបានចូលរួមសកម្មភាពជួយសង្គ្រោះនៅតំបន់គូម៉ាម៉ូតុ
បានទទួលពាក្យកោតសរសើរពីឯកឧត្តមឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន

សិក្ខាកាមខ្មែរដែលបានចូលរួមសកម្មភាពជួយសង្គ្រោះនៅតំបន់គូម៉ាម៉ូតុបានទទួលពាក្យកោតសរសើរពីឯកឧត្តមឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន

ឯកឧត្តម អ៊ឹង រចនា ឯកអគ្គរាជទូតកម្ពុជា(ឆ្វេង) និង លោក ហ៊ី ភីរ៉ូ

លោកហ៊ីភីរ៉ូដែលជាសិក្ខាកាម(ផ្នែកសំណង់/គ្រឿងម៉ាស៊ីន)នៅទីក្រុងហ្វូគូអូកាបានចូលរួមសកម្មភាពជួយសង្គ្រោះនៅតំបន់ដែលងងុលប៉ះពាល់ដោយភ្លៀងធ្លាក់ខ្លាំងនិងទឹកជំនន់នៅខេត្តគូម៉ាម៉ូតុដែរបានកើតឡើងនៅខែកក្កដា។លោកបានចូលរួមក្នុងកម្មវិធីសំណេះសំណាលដោយរៀបចំឡើងដោយស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន។

នៅថ្ងៃទី៩ខែសីហាឯកឧត្តម អ៊ឹង រចនាឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុនបានអញ្ជើញបងប្អូនខ្មែរចូលរួមក្នុងកម្មវិធីសំណេះសំណាលហើយសិក្ខាកាមរបស់សហជីពយើងក៏បានចូលរួមផងដែរ។ឯកឧត្តមបានដឹងលឺអំពីសកម្មភាពស្ម័គ្រចិត្តនៅតំបន់ងងុលគ្រោះរបស់ក្រុមហ៊ុនសំណង់រីយ៉ូស៊ីងដែលលោកភីរ៉ូកំពុងតែបម្រើការផងដែរ។

ក្នុងឱកាសដែលឯកឧត្តមឯកអគ្គរាជទូតកំពុងតែមានប្រសាសន៏ឯកឧត្តមប្រឹក្សាការងារបានសួរថា「តើសិក្ខាកាមខ្មែរដែលបានចូលរួមសកម្មភាពជួយសង្គ្រោះនៅតំបន់គូម៉ាម៉ូតុមានវត្តមាននៅទីនេះទេ?」សហជីពបានប្រាប់ពីកន្លែងអង្គុយនឹងបានជូនកាសែតលេខ៧របស់សហជីពបន្ទាប់មកឯកឧត្តមប្រឹក្សាការងារបានជូនទៅឯកឧត្តមឯកអគ្គរាជទូត។ឯកឧត្តមឯកអគ្គរាជទូតក៏បានលើកឡើងពីសកម្មភាពរបស់លោកការម្យាៗលោកការម្យាក៏បានក្រោកឈរនិងបានរៀបរាប់អំពីសកម្មភាពនិងឆ្លើយនូវសំណួររបស់ឯកឧត្តម។លោកភីរ៉ូពិតជាមានសេចក្តីរីករាយក្រៃលែងនូវពេលដែលបានជួបសំណេះសំណាលផ្ទាល់ជាមួយឯកឧត្តមដែលជាបុគ្គលមិនងាយនឹងបានជួប។សម្រាប់លោកភីរ៉ូសកម្មភាពស្ម័គ្រចិត្តនេះពិតជាបទពិសោធន៏ដ៏ល្អមួយមិនត្រឹមតែប៉ុណ្ណោះដំណឹងនេះបានដឹងលឺទៅដល់ឯកឧត្តមឯកអគ្គរាជទូតទៀតផង!សម្រាប់ខ្ញុំ(បុគ្គលិកសហជីព)ក៏ជាបទពិសោធន៏ដែលមិនអាចកាត់ថ្លៃបានដែរ។ **(លោកស្រីតារកេជាក់យ៉ូកាក់/សាខាយ៉ូស្សូ)**

●ចំណាប់អារម្មណ៍របស់លោកភីរ៉ូ

ឯកឧត្តមឯកអគ្គរាជទូតបានសរសើរថា「យើងអាចតបស្នងសងគុណប្រទេសជប៉ុនវិញបានគឺពិតជាល្អណាស់ព្រោះប្រទេសនេះតែងតែជួយប្រទេសយើងរហូតមក」។លោកបានប្រាប់រឿងដែលបានឯកឧត្តមឯកអគ្គរាជទូតសរសើរអំពីសកម្មភាពស្ម័គ្រចិត្តរបស់ខ្លួនទៅកាន់ឪពុកម្តាយ។ឪពុកម្តាយបានផ្តាំថា「ទង្វើនេះពិតជាល្អណាស់សម្រាប់ប្រទេសជាតិនិងមនុស្សជាតិប៉ុន្តែសូមប្រុងប្រយ័ត្នផងកុំអោយមានគ្រោះថ្នាក់ដល់ខ្លួន」។លោកបានបន្ថែមទៀតថាដំបូងខ្ញុំពិតជាមានអារម្មណ៍ភ័យខ្លាចណាស់ព្រោះមិនដែលជួបគ្រោះធម្មជាតិបែបនេះពីមុននោះទេ។ដោយសេចក្តីអាណិតរបស់ខ្ញុំទៅលើបងប្អូនដែលងងុគ្រោះ។ខ្ញុំមានតែខំប្រឹងប្រែងជួយជាកំលាំងនិងបន់ស្រន់សុំក្តីសុខដល់ពួកគេ។ក្រោយពីបានចូលរួមសកម្មភាពស្ម័គ្រចិត្តនេះហើយខ្ញុំយល់ថាការស្តាប់ព័ត៌មានឬទទួលយកដំណឹងពិតជាសំខាន់ណាស់។ដូចជាការស្តាប់ព័ត៌មានផ្សេងៗនិងព័ត៌មានជម្លៀសខ្លួនរបស់សាលាក្រុងជាដើមហើយចាំបាច់ត្រូវត្រៀមស្បៀងផងដែរ។

ការត្រៀមជើម្បីសុវត្ថិភាព!កម្មវិធីការពារគ្រោះមហន្តរាយ
<ឥតគិតថ្លៃ・ភាសាខ្មែរ>

ភ្លៀងធ្លាក់ខ្លាំងនៅខែកក្កដាបានសម្លាប់សិក្ខាកាមជំនាញនៅខេត្តគូម៉ាម៉ូតូទោះបីវាមិនទាក់ទងនឹងសហជីពរបស់យើងខ្ញុំក៏ដោយចុះយើងសូមចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំបំផុត។

កម្មវិធីនិងគេហទំព័រដែលមានភាពងាយស្រួលក្នុងករណីមានគ្រោះមហន្តរាយ

នេះជាការណែនាំកម្មវិធីស្មាតហ្វូននិងគេហទំព័រដែលអ្នកអាចរៀនអំពីព័ត៌មានគ្រោះមហន្តរាយនៅជប៉ុនជាភាសាខ្មែរៗងាយស្រួលក្នុងការទាញយកហើយបិទភ្ជាប់វានៅកន្លែងដែលអ្នកអាចមើលឃើញភ្លាមៗ។ប្រើកម្មវិធីការពារគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះជីវិតអ្នកយ៉ាងឆាប់រហ័ស។

ពលករជំនាញជាអ្វី?

នៅថ្ងៃទី 1 ខែមេសាឆ្នាំ 2019 ទិដ្ឋាការការងារថ្មី (លក្ខណសម្បត្តិនៃការស្នាក់នៅ) សម្រាប់ "ពលករជំនាញ" ត្រូវបានបង្កើតឡើង។ជនបរទេសដែលចង់ទៅធ្វើការនៅប្រទេសជប៉ុនបន្ទាប់ពីបានបញ្ចប់ការបណ្តុះបណ្តាលសិក្ខាកាមជំនាញមានគុណសម្បត្តិដូចខាងក្រោម។

・ប្រសិនបើអ្នកបញ្ចប់ការបណ្តុះបណ្តាលសិក្ខាកាមជំនាញ 2ហ្គូឬ 3ហ្គូអ្នកនឹងអាចប្តូរទៅ "ពលករជំនាញ 1ហ្គូ" ដោយមិនចាំបាច់ប្រលងជំនាញនិងតេស្តវាយតម្លៃភាសាជប៉ុនទេ។

・ប្រាក់ខែស្មើនឹងខ្ពស់ជាងជនជាតិជប៉ុន

・អាចផ្លាស់ប្តូរការងារប្រសិនបើស្ថិតក្នុងប្រភេទជំនាញដូចគ្នា

・ប្រសិនបើអ្នកធ្វើការដោយពលករជំនាញ 1ហ្គូរយៈពេល 5 ឆ្នាំចប់អ្នកអាចប្តូរទៅពលករជំនាញ 2ហ្គូហើយធ្វើការដោយគ្មានកំណត់។

・ប្រសិនបើអ្នកក្លាយជាពលករជំនាញ 2ហ្គូក្រុមគ្រួសារអ្នកក៏អាចស្នាក់នៅប្រទេសជប៉ុនបានដែរ។

ពលករជំនាញគឺខុសគ្នាឆ្ងាយពីប្រព័ន្ធបណ្តុះបណ្តាលសិក្ខាកាមជំនាញ។ត្រូវប្រាកដថាអ្នកយល់ពីភាពខុសគ្នាដោយការពិចារណា។

	សិក្ខាកាម	ពលករជំនាញ 1ហ្គូ
គោល បំណង	មិនមែនជាទាល់តែខ្លាំងពលកម្មនោះទេគឺជាប្រព័ន្ធសម្រាប់ប្រទេសជប៉ុនផ្ទេរបច្ចេកវិទ្យាទៅក្រៅប្រទេសនឹងចូលរួមចំណែកអន្តរជាតិ	ទិដ្ឋាការការងារ (ស្ថានភាពស្នាក់នៅ) ដែលអាចទទួលបានដោយជនបរទេសដែលត្រូវបានគេទទួលស្គាល់ថាអាចធ្វើការបានភ្លាមៗនៅក្នុងឧស្សាហកម្មដែលកង្វះខាតកម្លាំងពលកម្ម
រយៈ ពេ លនៃ ការ ស្នាក់ នៅ	ការបណ្តុះបណ្តាលជំនាញ1ហ្គូ ដល់ 3ហ្គូ សរុបរហូតដល់ 5ឆ្នាំ	សរុប 5 ឆ្នាំ (ពលករជំនាញ 2ហ្គូ គ្មានកំណត់)
ការ ប្រ លងនៅ ពេ លចូលប្រ ទេ ស	គ្មាន (មានតេស្តជំនាញភាសាជប៉ុនសំរាប់តែបុគ្គលិកថៃទាំប៉ុណ្ណោះ)	បញ្ជាក់កំរិតជំនាញ និងកំរិតភាសាជប៉ុន(អ្នកដែលបានបញ្ចប់ការបណ្តុះបណ្តាលជាសិក្ខាកាមជំនាញ 2ហ្គូ ដោយដោតជ័យត្រូវបានលើកលែងពីការប្រឡង)
ផ្លាស់ ប្តូរ ក្រុ ម ហ៊ុ ន・ផ្លាស់ ប្តូរ ការ ងារ	ជាគោលការណ៍មិនអាចធ្វើទៅបាន។ ទោះយ៉ាងណាក៏ដោយប្រសិនបើមិនអាចជៀសវាងបានថាអ្នកអនុវត្តក្បួនធនឬប្រសិនបើមានការផ្លាស់ប្តូរពីថ្នាក់ជំនាញ 2ហ្គូដល់ 3ហ្គូ នោះការផ្ទេរអាចធ្វើទៅបាន។	អ្នកអាចផ្លាស់ប្តូរការងារបានប្រសិនបើប្រភេទជំនាញដូចគ្នា
ការ ស្នាក់ នៅ របស់ គ្រួ សារ	មិនមែន	មិនមែន (ពលករជំនាញ2ហ្គូ មាន)

អំពីប្រាក់ឈ្នួលអប្បបរមា

ប្រាក់ឈ្នួលអប្បបរមាមាន2ប្រភេទ។

1 ប្រាក់ឈ្នួលអប្បបរមាតាមតំបន់/ ប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានកំណត់សម្រាប់ខេត្តនីមួយៗ

2 ប្រាក់ឈ្នួលអប្បបរមាដែលបានបញ្ជាក់ (តាមឧស្សាហកម្ម) / ប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់សម្រាប់ឧស្សាហកម្ម / មុខរបរដាក់លាក់នីមួយៗ

ប្រាក់ឈ្នួលអប្បបរមាដាក់លាក់ត្រូវបានកំណត់សម្រាប់ខេត្តនីមួយៗផងដែរប៉ុន្តែបើទោះបីជាការកាន់កាប់ដូចគ្នាត្រូវបានកំណត់នៅក្នុងអាណាខេត្តAក៏ដោយវាប្រហែលជាមិនមាននៅក្នុងអាណាខេត្តBទេ។

ប្រសិនបើមានករណីក្នុងតំបន់និងករណីដាក់លាក់ខ្ពស់ជាងនេះនឹងក្លាយជាប្រាក់ឈ្នួលអប្បបរមា។

ឧទាហរណ៍ប្រសិនបើប្រាក់ឈ្នួលអប្បបរមាតាមតំបន់គឺ 800យ៉ែនក្នុងមួយម៉ោងហើយប្រាក់ឈ្នួលអប្បបរមាដែលបានបញ្ជាក់គឺ 850យ៉ែនក្នុងមួយម៉ោងអ្នកត្រូវបង់ប្រាក់ឈ្នួល 850យ៉ែនឬច្រើនជាងនេះ។ប្រាក់ឈ្នួលអប្បបរមាត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំចាប់ពីខែ10ដល់ខែ12។